*កិច្ចប្រជុំកំពូលអាស៊ានបូកបី លើកទី ២៣*

ក្នុងនាមជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, នារសៀលថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០២០, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ បន្តចូលរួមកិច្ចប្រជុំកំពូល **"អាស៊ានបូកបី លើកទី ២៣"** តាមប្រព័ន្ធវីដេអូ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ កិច្ចប្រជុំនេះដឹកនាំដោយឯកឧត្តម **ង្វៀន សួន ហ៊្វុក (Nguyen Xuan Phuc)** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

ថ្នាក់ដឹកនាំនៃអាស៊ានបូកបី បានពិភាក្សា និងបញ្ជាក់នូវការប្តេជ្ញាចិត្តរបស់អាស៊ានបូកបី ក្នុងការលើកកម្ពស់សន្តិភាព, ស្ថិរភាព និងវិបុលភាពនៅក្នុងតំបន់ តាមរយៈការគាំទ្រ និងការចូលរួមចំណែករបស់ប្រទេសបូកបី ចំពោះគំនិតផ្តួចផ្តើមនានា សំដៅជួយដោះស្រាយបញ្ហាបន្ទាន់ ក្នុងអំឡុងពេលវិបត្តិនៃជំងឺកូវីដ-១៩ និងសម្រាប់អនាគតដូចជា៖ **"កិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (CMIM)"**, **"ការបង្កើតមូលនិធិអាស៊ានឆ្លើយតបជំងឺកូវីដ-១៩"** និង **"ការស្តុកបម្រុងបរិក្ខារវេជ្ជសាស្ត្រចាំបាច់នានារបស់អាស៊ានបូកបី សម្រាប់តម្រូវការបន្ទាន់ផ្នែកសុខភាពសាធារណៈ"** ។

ឈរលើស្មារតីសាមគ្គីភាព និងសហប្រតិបត្តិការខ្ពស់រវាងអាស៊ានបូកបី, អង្គប្រជុំ បានបង្ហាញនូវការគាំទ្រ និងឆន្ទៈរួមយ៉ាងមុតមាំលើការស្រាវជ្រាវ, អភិវឌ្ឍ និងផលិតវ៉ាក់សាំងឱ្យសម្រេចបាននាពេលឆាប់ៗនេះ ក៏ដូចជា ការចែកចាយវ៉ាក់សាំងនេះ ឱ្យបានទាន់ពេលវេលា ក្នុងតម្លៃសមស្រប សម្រាប់ប្រជាជនទាំងអស់គ្នា ។ ថ្នាក់ដឹកនាំនៃអាស៊ានបូកបី ក៏បានធ្វើការវាយតម្លៃខ្ពស់ ចំពោះកិច្ចសហប្រតិបត្តិការ និងការចូលរួមជួយជ្រោមជ្រែងរបស់ប្រទេសបូកបី ក្នុងការជំរុញការស្តារ និងការងើបឡើងវិញនៃសង្គម-សេដ្ឋកិច្ចនៅក្នុងតំបន់ តាមរយៈការបើកចំហរលំហូរពាណិជ្ជកម្មសេរី, វិនិយោគ និងការស្តារឡើងវិញនៃខ្សែច្រវាក់ផលិតកម្មនៅក្នុងតំបន់ ។ ក្នុងន័យនេះ, ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP) នាថ្ងៃស្អែក ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២០ គឺជាសក្ខីភាពជាក់ស្តែងនៃសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ប្រទេសអាស៊ានបូកបីនេះ ក្នុងការជំរុញកំណើន, ការលើកកម្ពស់ ភាពរឹងមាំ និង ភាពធន់នៃសេដ្ឋកិច្ចបន្ថែមមួយកម្រិតទៀត ។ នៅក្នុងដំណាក់កាលនៃការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញនេះ ថ្នាក់ដឹកនាំអាស៊ានបូកបី ក៏បានកត់សម្គាល់ពីសារៈសំខាន់នៃការតភ្ជាប់នៅក្នុងតំបន់ និង នវានុវត្តន៍ផ្នែកបច្ចេកវិទ្យាឌីជីថល ដែលនឹងក្លាយទៅជាសសរស្តម្ភដ៏ចម្បង នៃការអភិវឌ្ឍប្រកបដោយចីរភាព ។

ជាលទ្ធផល, ក្រោមស្មារតីសាមគ្គីភាព, ការរក្សាបាននូវស្មារតី និងយន្តការពហុភាគីនិយម និងការរួបរួមជាថាមពលភាព ក្នុងការដោះស្រាយបញ្ហាកម្រិតតំបន់ និងសកល, ថ្នាក់ដឹកនាំអាស៊ានបូកបី ក៏បានប្តេជ្ញាចិត្តខ្ពស់ក្នុងការរក្សាសន្តិភាព និងស្ថិរភាពនៅក្នុងតំបន់ តាមរយៈយន្តការដោះស្រាយបញ្ហានានា ដោយសន្តិវិធី, ការអនុលោមតាម

គោលការណ៍នៃច្បាប់អន្តរជាតិ និងការរំសាយអាវុធនុយក្លេអែរនៅឧបទ្វីបកូរ៉េ ។ ស្របគ្នានេះដែរ, ថ្នាក់ដឹកនាំអាស៊ាន បូលបី បានឯកភាពគ្នា ចំពោះការបង្កើត “**ក្រុមការងារអាស៊ានបូកបីដោះស្រាយជំងឺរាតត្បាត**”, “**ការស្តុកបម្រុងបរិក្ខារវេជ្ជសាស្ត្រចាំបាច់នានារបស់អាស៊ានបូកបី សម្រាប់តម្រូវការបន្ទាន់ផ្នែកសុខភាពសាធារណៈ**” និងការដាក់ចេញនូវ “**សេចក្តីប្រកាសរបស់ថ្នាក់ដឹកនាំអាស៊ានបូកបី ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការអាស៊ានបូកបីសម្រាប់ភាពរឹងមាំសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងពេលប្រឈមទៅនឹងបញ្ហាកើតមានឡើង**” ដើម្បីបង្កើនសមត្ថភាព និងពង្រឹងសហប្រតិបត្តិ-ការ ជំរុញដល់ការឆ្លើយតបទៅនឹងវិបត្តិសេដ្ឋកិច្ច-ហិរញ្ញវត្ថុ និងបញ្ហាប្រឈមដទៃទៀត នៅក្នុងតំបន់ និងសកល នាពេលអនាគត ។